ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ២២/១០-ញូ អាកឃីត

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ សេង រ៉ូចហ៊ុន

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ លីវ សុវណ្ណា

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ញូ អាកឃីត ហ្វាមេន ហ្វាកធើរី លីមីធីត

អាសយដ្ឋាន : ភូមិត្រពាំងភូមិ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៧៩០ ៩៩០ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

- លោក ប៊ុន ថា ប្រធានរដ្ឋបាល

២- ភាគីកម្មករនិយោជិត

ក/-ឈ្មោះ : - សហជីពកម្មករកាត់ដេរ រោងចក្រ អាកឃីត

- សហព័ន្ធសហជីពខ្មែរ

អាសយដ្ឋាន : ក្នុងរោងចក្រ អាកឃីត សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ៦៩៨ ១២៩ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិតៈ

១- លោក ម៉ុម ធន អ្នកដោះស្រាយវិវាទនៃសហព័ន្ធសហជីពខ្មែរ

| | |
|---|---|
| ២- លោក ជា សុផា | អ្នកដោះស្រាយវិវាទនៃសហព័ន្ធសហជីពខ្មែរ |
| ៣- លោក អ៊ុត សុផា | ប្រធានសហជីពកម្មករកាត់ដេររោងចក្រ អាកឃីត |
| ៤- លោក ឌុច ផល្លី | លេខាធិការសហជីព |
| ៥- លោក ឡោ សំណាង | ទីប្រឹក្សាសហជីព |
| ៦- លោក រី គីមយ៉េង | ជំនួយការសហជីព |
| ៧- លោក សយ ចន្ធូ | ជំនួយការសហជីព |

ខ/-ឈ្មោះ : **- សហជីពយុវជនខ្មែរ នៃរោងចក្រ ញូ អាកឃីត**

**- សហព័ន្ធសហជីពយុវជនខ្មែរ**

អាសយដ្ឋាន : ភូមិត្រពាំងភូមិ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល

លេខទូរស័ព្ទ : គ្មាន ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត: **( មិនបានមកចូលរួមក្នុងដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ )**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ចំនួន ២០០០ រៀល ជូនកម្មករនៅពេលក្រុមហ៊ុនឱ្យកម្មករធ្វើការនៅថ្ងៃបុណ្យ និងថ្ងៃអាទិត្យ ហើយត្រូវផ្ដល់ជូនផងដែរ ចំពោះកម្មករធ្វើការថែមម៉ោង ៤:០០ ដល់ម៉ោង ៨:០០ ។

២- សុំឱ្យក្រុមហ៊ុនរៀបចំសង្វាក់ផលិតកម្មនៅអាគារ C មានការកំណត់ចំនួន និងការផ្ដល់ប្រាក់រង្វាន់ជូនកម្មករដូចអាគារ A និងអាគារ B ដែរ ពីព្រោះ វាជាក្រុមហ៊ុនតែមួយ ។

៣- សុំឱ្យក្រុមហ៊ុនឧបត្ថមប្រាក់ដល់កម្មករដែលមានជំនាញជាក់ស្ដែង ។

៤- សុំឱ្យកម្មករចេញម៉ោង ៣:០០ រសៀល នៅថ្ងៃសៅរ៍ រាល់សប្ដាហ៍ គឺកាត់បន្ថយម៉ោងធ្វើការចំនួនមួយម៉ោងនៅថ្ងៃសៅរ៍ចុងសប្ដាហ៍ ។

៥- សុំឱ្យក្រុមហ៊ុនបើកទ្វារចូលបន្ទប់ពេទ្យត្រង់អាគារ B និងទ្វារធំ ។

៦- សុំឱ្យក្រុមហ៊ុនរៀបចំប្ដូរច្រកចេញចូលចាស់ដូចដើមវិញ ព្រោះកន្លែងថ្មីមានការកកស្ទះណាស់ ។

៧- សុំឱ្យក្រុមហ៊ុនរៀបចំប្រធានក្រុមចិននៅអាគារ B ដែលពិបាកសុំច្បាប់ នៅពេលកម្មករសុំម្ដងម្កាលសូមឱ្យមានភាពងាយស្រួល ។

៨- សុំឱ្យក្រុមហ៊ុនទំលាក់ចំនួនកំណត់នៅអាគារ B ដូចដែលធ្លាប់បានអនុវត្តពីមុនមក ។

៩- សុំឱ្យក្រុមហ៊ុនបញ្ឈប់អាចែគ្រប់គ្រងនៅអាគារ C ចោលពីក្រុមហ៊ុនញូអាកឃីត ។

១០- សុំឱ្យក្រុមហ៊ុនបន្ថែមម៉ាស៊ីនសំរាប់ស្ទេនមេដៃនៅអាគារ C ចំនួនពីរទៀត ។

THE ARBITRATION COUNCIL

១១- សុំឱ្យក្រុមហ៊ុនរៀបចំប្តូរធុងទឹកឱ្យបានធំជាងនេះ នៅគ្រប់១អាគារ ។

១២- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានធុងទឹកក្តៅ ត្រជាក់សំរាប់កម្មការិនីដែលមានផ្ទៃពោះនៅគ្រប់១អាគារ

១៣- សុំឱ្យក្រុមហ៊ុនរៀបចំប្តូរច្រកចេញចូលចាស់ដូចមុនវិញ ព្រោះកន្លែងថ្មីមានការកកស្ទះណាស់ ។

១៤- សុំឱ្យក្រុមហ៊ុនបើកផ្លិតទឹកឱ្យបានគ្រប់១អាគារ ។

១៥- សុំឱ្យក្រុមហ៊ុនរៀបចំធុងបាសសំរាប់ស្តាប់នៅក្នុងអាគារ ។

១៦- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានតុសំរាប់បងប្អូនកម្មករហូបបាយ ។

១៧- សុំឱ្យក្រុមហ៊ុនបន្ថែមលុយបាយមួយម៉ោង ៥០០ រៀល ។

១៨- នៅពេលក្រុមហ៊ុនធ្វើការបន្ថែមម៉ោងភ្លឺ សូមឱ្យមានបាយម្ហូបគ្រប់គ្រាន់នៅគ្រប់១អាគារ ។

១៩- សុំឱ្យក្រុមហ៊ុនកំណត់ចំនួនកំណត់បន្តិច ។

២០- សុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានថ្លៃធ្វើដំណើរ និងស្នាក់នៅចំនួន ១០ ដុល្លារគ្រប់១អាគារ ។

២១- សុំឱ្យក្រុមហ៊ុនរៀបចំរចនាសម្ព័ន្ធអាគារ C ឱ្យដូចអាគារ A និង B ។

២២- នៅពេលកម្មករធ្វើការថ្ងៃអាទិត្យ សូមឱ្យចេញជាទឹកលុយនៅក្នុងក្រដាសបើកប្រាក់ខែនៅគ្រប់១អាគារ ។

២៣- នៅពេលក្រុមហ៊ុនដោះស្រាយរឿងអ្វីមួយហើយ សូមឱ្យក្រុមហ៊ុនធ្វើការអនុវត្តតាមផង ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៩៥/១០ កប/កណ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០។

## សវនាការ និង សន្ទេបនីតិវិធី

ទីកន្លែងសវនាការ : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៩៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១០ (វេលាម៉ោង ១៤:00 នាទី រសៀល) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញពីររូបធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន ២៣ ចំណុច នៅក្រុមហ៊ុន ញូ អាកឃីត ប៉ុន្តែ ការផ្សះផ្សានេះមិនអាចដំណើរការបានទេ ដោយសារភាគីវិវាទក្រុមហ៊ុន និងសហជីព (សហជីពយុវជនខ្មែរ និងសហជីពខ្មែរ) មិនទាន់បានទំនាក់ទំនងគ្នានៅឡើយ ។ ហេតុនេះ ភាគីក្រុមហ៊ុនបានសំណូមពរឱ្យអ្នកផ្សះផ្សាលើកការផ្សះផ្សាទៅវេលាម៉ោង ១៣:៣០ នាទី រសៀលវិញ ។ រហូតមកដល់ពេលកំណត់នៅម៉ោង ១៣:៣០ នាទីរសៀល ភាគីក្រុមហ៊ុន និងសហជីពខ្មែរបានមកចូលរួមផ្សះផ្សាតាមការកំណត់ ។ ប៉ុន្តែ សហជីពយុវជនខ្មែរ មិនបានមកចូលរួមទេ (អវត្តមានពីព្រោះមិនអាចទំនាក់ទំនងបាន) ។ ដូច្នេះ ការផ្សះផ្សាត្រូវលើកទៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ០៩:០០នាទីព្រឹក ។

នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០ វេលាម៉ោង ០៩:០០ នាទីព្រឹក ភាគីក្រុមហ៊ុនបានមកចូលរួមផ្សះផ្សាតាមការកំណត់ ។ ចំណែកឯ ភាគីសហជីព (សហជីពយុវជនខ្មែរ និងសហជីពខ្មែរ) មិនបានមកចូលរួមទេ (អវត្តមានដោយគ្មានមូលហេតុច្បាស់លាស់) ។ ដូច្នេះ ចំណុចមិនសះជាទាំង ២៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ តាមរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ០៩៥ កប/កណ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីសហជីពប្រចាំរោងចក្រ (សហជីពយុវជនខ្មែរ និងសហជីពខ្មែរ) មកជ្រើសរើសអាជ្ញាកណ្តាលដើម្បីដំណើរការដោះស្រាយការទាមទាររបស់ខ្លួន នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ពេលនោះ លោក នៅ ទិត្ថា មន្ត្រីរបស់សហព័ន្ធសហជីពយុវជនខ្មែរបានបញ្ជាក់ថា សហជីពយុវជនខ្មែរមិនពាក់ព័ន្ធក្នុងបណ្តឹងទាមទារក្នុងសំណុំរឿងនេះទេ ហើយក៏មិនមកចូលរួមក្នុងការជ្រើសរើសអាជ្ញាកណ្តាលផងដែរ ។ ប៉ុន្តែ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា នៅក្នុងពាក្យបណ្តឹង គឺសហជីពយុវជនខ្មែរជាអ្នកទាមទារក្នុងសំណុំរឿង ដែលមានចំណុចវិវាទទាមទារចំនួន ១៨ ចំណុច ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ ។ ដោយឡែក ភាគីក្រុមហ៊ុន និងសហជីពខ្មែរបានមកជ្រើសរើសអាជ្ញាកណ្តាល ស្របតាមនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយក៏បានមកចូលរួមសវនាការតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ ។

សហជីពខ្មែរបានបញ្ជាក់នៅក្នុងសវនាការថា សហជីពមិនបានដឹងពីមូលហេតុដែលនាំឱ្យការទាមទាររបស់ខ្លួនចំនួន ០៥ ចំណុច ក្នុងចំណោមចំណុចវិវាទចំនួន ២៣ ចំណុច ដែលត្រូវបានដាក់បញ្ចូលជាមួយនឹងការទាមទាររបស់សហជីពយុវជនខ្មែរទៅក្នុងសំណុំរឿងនេះទេ ។

ហេតុនេះហើយ សហជីពខ្មែរ សុំបដិសេធចំណុចវិវាទទាំង ០៥ ចំណុច នៅក្នុងបណ្តឹងទាមទារជាមួយសហជីពយុវជនខ្មែរនេះពីព្រោះចំណុចទាមទារទាំង ០៥ ចំណុចនេះ ត្រូវបានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ខេត្តកណ្ដាល បានផ្សះផ្សារួចហើយ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ និងកំពុងដំណើរការដោះស្រាយ។ ចំណែក ឯ ភាគីក្រុមហ៊ុន បានឯកភាពទៅនឹងការលើកឡើងនេះ ហើយស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាល អនុវត្តតាមច្បាប់។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទក្នុងសំណុំរឿងនេះដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

ក- សហជីពកម្មករកាត់ដេរ រោងចក្រ អាកឃីត :

១- លិខិតរបស់សហព័ន្ធសហជីពខ្មែរលេខ ០៣៦/១០ សសខ គោរពជូនឯកឧត្តមប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាល ខេត្តកណ្ដាល ស្ដីពីការសុំជួយដោះស្រាយនូវការទាមទាររបស់កម្មករធ្វើការនៅរោងចក្រ ញូ អាកឃីត ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ ។

២- លិខិតអញ្ជើញផ្សះផ្សាវិវាទការងាររួមរបស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈលេខ ១៤០/១០ កប/កណ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ។

៣- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារលេខ ៦៥៧ កប/អក/វក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ជំរាបជូនលោកប្រធានសហជីពកម្មករកាតដេររោងចក្រ ញូ អាកឃីត ស្ដីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២ ។

៤- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករកាត់ដេររោងចក្រ ញូអាកឃីត ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ ។

ខ- សហជីពយុវជនខ្មែរ នៃក្រុមហ៊ុន ញូ អាកឃីត : គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញូ អាកឃីត លេខ ០៩៥/១០ កប/កណ ចុះ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ញូ អាកឃីត ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៣២ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៣៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

អង្គហេតុ ដែលទាក់ទងនឹងការទាមទារមិនត្រូវបានលើកឡើងនៅក្នុងអង្គសវនាការទេ ដោយហេតុថា សហជីពយុវជនខ្មែរ អវត្តមាននៅថ្ងៃសវនាការ ហើយសហជីពខ្មែរក៏បានបដិសេធការទាមទាររបស់ខ្លួននៅក្នុងសំណុំរឿងនេះដែរ។

**ហេតុផលនៃសេចក្តីសម្រេច**

**ក- ករណីសហជីពខ្មែរ :**

នៅក្នុងសវនាការ សហជីពខ្មែរបានបញ្ជាក់ថា សហជីពខ្មែរ សុំបដិសេធការទាមទារនៅក្នុងសំណុំរឿងនេះ ពីព្រោះ សហជីពមិនបានធ្វើការទាមទាទេ ដោយហេតុ ចំណុចវិវាទដែលសហជីពខ្មែរ ទាមទារចំនួន ០៥ ចំណុច ក្នុងចំណោមចំណុចវិវាទចំនួន ២៣ ចំណុច នៅក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សារួចហើយ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០ ហើយកំពុងដំណើរការដោះស្រាយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពខ្មែរបានបដិសេធការទាមទាររបស់ខ្លួន។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពខ្មែរ មិនបានធ្វើការទាមទារនៅក្នុងសំណុំរឿងនេះទេ។

**ខ- ករណីសហជីពយុវជនខ្មែរ :**

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាលើករណីសហជីពយុវជនខ្មែរនេះ ដូចខាងក្រោម:

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានបកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាច*

*បញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន "។*

តាមខ្លឹមសារនៃវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ខាងលើ មានន័យថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់ ក្នុងករណី ភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល (អវត្តមានរបស់ភាគី)។ នៅក្នុងសំណុំរឿងនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការទំនាក់ទំនងជាមួយសហជីពយុវជនខ្មែរជាបន្តបន្ទាប់ ចាប់តាំងពីលេខាធិការដ្ឋានបានទទួលសំណុំរឿងនេះ ពីមន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ រួចមក ដូចជា នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១០ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះហៅតំណាងសហជីពមកជ្រើសរើសអាជ្ញាកណ្តាល។ ប៉ុន្តែ ភាគីសហជីពមិនបានមកជ្រើសរើសអាជ្ញាកណ្តាលទេ ហើយក៏មិនបានចាត់តំណាងឱ្យមកជ្រើសរើសអាជ្ញាកណ្តាលក្នុងដំណើការរអាជ្ញាកណ្តាលដែរ គឺគ្រាន់តែបញ្ជាក់ថា ការទាមទារនៅក្នុងសំណុំរឿងនេះ មិនពាក់ព័ន្ធនឹងសហជីពយុវជនខ្មែរទេវិញ។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា នៅក្នុងពាក្យបណ្តឹងដើមរបស់សហជីពយុវជនខ្មែរចំនួន ១៨ ចំណុច ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ និងរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០៩៥/១០ កប/កណ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ បង្ហាញថា សហជីពយុវជនខ្មែរ ជាអ្នកទាមទារ។ មានន័យថា សហជីពយុវជនខ្មែរជាដើមបណ្តឹង។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការដែលសហជីពមិនបានមកបង្ហាញខ្លួន ឬមិនបានចាត់អ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាលនេះ គឺសហជីពយុវជនខ្មែរបានបោះបង់ការទាមទាររបស់ខ្លួន។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាង នៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ ភាគីសហជីពយុវជនខ្មែរ ដែលជាភាគីដើមបណ្តឹង មិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណី ភាគីដើមបណ្តឹងមិនមកបង្ហាញខ្លួន ឬចាត់អ្នកតំណាង ក្នុងដំណើរការរអាជ្ញាកណ្តាល ធ្វើឱ្យភាគីបាត់បង់ឱកាស ក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយសុទ្ធចិត្តរបស់ភាគីសហជីពយុវជនខ្មែរ ក្នុងការយកវិវាទការងាររបស់ខ្លួន មកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សារអាជ្ញាកណ្តាលនោះឡើយ។

ដូច្នេះ ជាសរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿង លេខ ២២/១០-ញ អាកឃីត នេះ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផល ដូចបានពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ :

## សម្រេច និង បង្គាប់

សម្រេច បិទសំណុំរឿង លេខ ២២/១០-៣ អាកឃីត នេះ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **សេខ ទូចហ៊ុន**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លីម សុវណ្ណា**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនយោ**

ហត្ថលេខា: ------------------------------